BMI0112

# សម្ភាសន៍ជាមួយឈ្មោះ ស៊ើន យ៉ង ភេទប្រុស អាយុ៦០ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានក្រុមកងក្ងរ

## មុខងារបច្ចុប្បន្នៈ កសិករ

## សព្វថ្ងៃរស់នៅភូមិគំរូ ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុធានី

## ០០:២៩:៥០

## ១៧ទំព័រ

ធានី ៖ ថ្ងៃហ្នឹងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ។ ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

យ៉ង ៖ បាទ! ខ្ញុំឈ្មោះ ស៊ើន យ៉ង ។

ធានី ៖ ឆ្នាំហ្នឹងអាយុប៉ុន្មានហើយ?

យ៉ង ៖ ខ្ញុំអាយុ៦០ហើយ ។

ធានី ៖ ស៊ើន?

យ៉ង ៖ ស៊ើន យ៉ង ។

ធានី ៖ សើន?

យ៉ង ៖ ស៊ើន ។

ធានី ៖ ស៊ើន យ៉ន?

យ៉ង ៖ យ៉ង ។

ធានី ៖ អាយុប៉ុន្មាន?

យ៉ង ៖ អាយុ៦០ហើយ ។

ធានី ៖ ៦០ឆ្នាំ ពូមានស្រុកកំណើតនៅណាដែរ?

យ៉ង ៖ បាទ! ស្រុកកំណើតនៅនឹងភូមិថ្មពួក ។

ធានី ៖ ភូមិថ្មពួក ឃុំអីដែរ?

យ៉ង ៖ ឃុំថ្មពួកពីដើមមិញ សព្វថ្ងៃភូមិគំរូ ស្រុកកំណើតដែលកើតនៅថ្មពួក ។

ធានី ៖ ស្រុកអីគេដែរ?

យ៉ង ៖ ស្រុកថ្មពួក ។

ធានី ៖ ខេត្ត?

យ៉េង ៖ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ចុះរាល់ថ្ងៃពូរស់នៅណាវិញ?

យ៉េង ៖ បាទ! ខ្ញុំរស់នៅភូមិគំរូដែលសម័យសម្តេចសីហនុគាត់បំបែកស្រុកមកនៅភូមិគំរូនេះ ។

ធានី ៖ ភូមិគំរូ ឃុំអីគេ?

យ៉េង ៖ ឃុំគំរូ ។

ធានី ៖ ឃុំគំរូដែរ?

យ៉េង ៖ បាទ! ឃុំគំរូ ។

ធានី ៖ ស្រុកអីគេ?

យ៉េង ៖ ស្រុកនឹង ស្រុកៗគំរូ ។

ធានី ៖ ស្រុកបន្ទាយមានជ័យ ឬស្រុកគំរូ?

យ៉េង ៖ បាទ! ស្រុកបន្ទាយមានជ័យ ។

ធានី ៖ អឺ! ស្រុកថ្មពួក ឬស្រុកអី ឥឡូវ ស្រុកយើង?

យ៉េង ៖ ឥឡូវភូមិគំរូ ឃុំគំរូ បើខេត្តៗបន្ទាយមានជ័យ ។

ធានី ៖ ស្រុកអីគេទៅ?

យ៉េង ៖ ស្រុកៗបន្ទាយមានជ័យយើងនឹង ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

យ៉េង ៖ បាទ! ខ្ញុំឈ្មោះ ស៊ើន យ៉េងនឹង ។

ធានី ៖ ឪពុកឈ្មោះអីគេ?

យ៉េង ៖ ឈ្មោះនែក! ហ៊ុន ស៊ើន ។

ធានី ៖ គាត់នៅរស់ទេ?

យ៉េង ៖ បាទ! គាត់នៅរស់ ។

ធានី ៖ រស់នៅភូមិណាវិញ?

យ៉េង ៖ ភូមិគំរូនេះឯង ។

ធានី ៖ ចុះម្តាយពូ?

យ៉េង ៖ ម្តាយខូចហើយ ។

ធានី ៖ ម្តាយឈ្មោះអីគេ?

យ៉ង ៖ ឈ្មោះនែក! យាយកាន ។

ធានី ៖ យាយកាន គាត់មានស្រុកកំណើតនៅណាវិញ?

យ៉ង ៖ កំណើតនៅថ្មពួក នៅតែនេះឯង ។

ធានី ៖ គាត់ស្លាប់ដោយសារអីដែរ?

យ៉ង ៖ ស្លាប់កាលសម័យ៣ឆ្នាំ ។

ធានី ៖ ដោយសារអីដែរ?

យ៉ង ៖ ដោយសារគាត់អត់ហូប អត់ស្បៀងអាហារ ពួកសម័យនោះ ពួកអត់បាយ ។

ធានី ៖ បងប្អូនពូមានប៉ុន្មាននាក់?

យ៉ង ៖ បងប្អូនខ្ញុំសព្វថ្ងៃនៅសល់៣នាក់ ។

ធានី ៖ ទាំងអស់មានប៉ុន្មាននាក់?

យ៉ង ៖ ទាំងអស់៧នាក់ ប៉ុនខូចសម័យ៣ឆ្នាំ ។

ធានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

យ៉ង ៖ ដែលនៅ?

ធានី ៖ អត់ទេទាំងអស់ បងប្អូនទាំងអស់?

យ៉ង ៖ ទាំងអស់ ប្រុស៤ ស្រី៣ ។

ធានី ៖ ខូចសម័យ៣ឆ្នាំប៉ុន្មាននាក់?

យ៉ង ៖ ខូចអស់៤នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉ង ៖ ស្រី២ ប្រុស២ ។

ធានី ៖ ដោយសារអីដែរបានគាត់ស្លាប់ចឹង?

យ៉ង ៖ ស្លាប់ដោយសារ ដែលគាត់អត់បាយអត់ទឹក កាលសម័យ៣ឆ្នាំ ។

ធានី ៖ ពូរៀបគ្រួសារឆ្នាំប៉ុន្មាន?

យ៉ង ៖ រៀបគ្រួសារឆ្នាំ៧៨ ។

ធានី ៖ គ្រួសារពូឈ្មោះអី?

យ៉ង ៖ ឈ្មោះ ជួប រឿង ។

ធានី ៖ ជួប រឿន?

យ៉ង ៖ ជួប រឿងៗ ។

ធានី ៖ អឿនៗ មានកូនប៉ុន្មាននាក់?

យ៉ង ៖ ខ្ញុំមានកូន៧នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉ង ៖ ស្រី៣ ប្រុស៤ ។

ធានី ៖ អូ! ដូចឪពុកពូដែរ ដូចគ្នា?

យ៉ង ៖ បាទ!

ធានី ៖ ពូរៀនបានថ្នាក់ទីប៉ុន្មានដែរកាលពីមុន?

យ៉ង ៖ កាលពីមុនខ្ញុំរៀនបានថ្នាក់ទី៧ អឺ!ទី៨ ។

ធានី ៖ ទី៨ៗពីដើម?

យ៉ង ៖ បាទ!

ធានី ៖ នៅសាលាណា?

យ៉ង ៖ សាលាថ្មពួក ។

ធានី ៖ ចង់ឲ្យពូរៀនរាប់ហេតុអីបានពូឈប់រៀន ហើយរហូតបានមកដល់ឥឡូវ កាលពីដំបូងមក?

យ៉ង ៖ កាលពីដំបូងមកដែលខ្ញុំឈប់រៀន ដោយសារខ្ញុំជីវភាពវាយ៉ាប់ផង វាគ្មានអ្នកណាជួយឪពុកម្ដាយ ខ្ញុំសម្រាក ខ្ញុំឈប់រៀន ។ ដល់ខ្ញុំឈប់រៀនមក ខ្ញុំបួសបាន២វស្សាៗហើយដល់ពេលចូលមក ខ្ញុំក៏ចាប់បានប្រពន្ធរហូតមកឆ្នាំ៧៤ ។

ធានី ៖ ដល់ពេលពូបួសៗនៅវត្តណាទៅ?

យ៉ង ៖ បាទ! បួសក្នុងវត្តថ្មពួកនេះឯង ។

ធានី ៖ បួសរៀនវត្តថ្មពួក?

យ៉ង ៖ បាទ! វត្តថ្មពួក ។

ធានី ៖ ពូឈប់រៀនឆ្នាំប៉ុន្មាន?

យ៉ង ៖ ខ្ញុំឈប់រៀនឆ្នាំ ៧១ ។

ធានី ៖ បន្ទាប់មកទៀតម៉េចពូថារៀបការៗហើយម៉េចទៀតទៅ?

យ៉ង ៖ បាទ! រៀបការទៅដល់នេះបានកូនមួយ បានកូនអាបងគេនេះមួយរហូតក៏ចូលមក៣ឆ្នាំ អាឆ្នាំ៧៥រហូតមកដល់៧៩ ។

ធានី ៖ ម៉េចទៀតពូ?

យ៉ន : ដល់នោះមកខ្ញុំបានកូន២នាក់ ដែលម្នាក់នោះប្រុស ម្នាក់នោះស្រីឆ្នាំ៧៦ៗបានកូនស្រីៗ ដល់ នេះ ដល់រហូតពាឆ្នាំប៉ុន្មានខែចប់មក ខ្ញុំរស់នៅក៏បានកូនបន្តៗមករហូតសព្វថ្ងៃកូនឡើង៦-៧នាក់ៗ

ធានី : ចឹងចង់សុំសួរពូថា ពេល៧៨ពូរៀបគ្រួសារហើយ ពូធ្វើអីទៀត?

យ៉ន : រៀបគ្រួសារហើយធ្វើស្រែចំការៗ

ធានី : នៅណាវិញ?

យ៉ន : នៅថ្មពួក អឺ! នៅភូមិគុំរូៗ

ធានី : ចឹងគ្រួសារលោកពូអ្នកស្រុកភូមិយើងដែរ?

យ៉ន : បាទ! ភូមិយើងនេះឯងៗ

ធានី : ចុះដល់ពេលឆ្នាំ៧៥ ពូធ្វើអីគេ?

យ៉ន : ៧៥ ខ្ញុំដើរតាមតែពលករដែលគេប្រើទៅនេះទៅនោះៗ

ធានី : ទៅណាទៅ?

យ៉ន : ចេះតែភ្ជួរទៅភ្ជួរៗ

ធានី : ចង់ឲ្យពូជួយរៀបរាប់ថាតាំងពីដំបូងមកម៉េច បានគេថាជារបបពាឆ្នាំ ចង់ឲ្យពូជួយរៀបរាប់ពីទិដ្ឋភាព ដំបូងថាធ្វើស្រែចំការ មានគ្រួសារមានអីចឹង ក្រោយចឹងម៉េចបានដើរថាមានខ្មែរក្រហមដែលចូលមកភូមិយើងដំបូង ឬក៏យ៉ាងម៉េចបាន?

យ៉ន : បាទ! ខ្មែរក្រហមចូលមកភូមិយើងដំបូងមកបានខាងនេះ បានគេចាត់ចែងក្រុមកងៗគេសម្រាប់ធ្វើស្រែចំការអាគេដឹកនាំរបស់សម័យពាឆ្នាំ ដែលគេកាន់កាប់នោះឯងៗ

ធានី : ចុះពូគេចាត់ចែងឲ្យធ្វើអីគេ?

យ៉ន : ភ្ជួររាស់ ស្ទូង ប៉ុន្តែអារឿងបាយចុកនេះវាគ្មានអីហូបស្រួលបួលទេ ម្នាក់ៗម៉ាកូនចានបបរទៀត វេទនាណាស់និយាយពីសម័យនោះៗ

ធានី : ចុះពូ អ្នកដែលចាត់ចែងដែលឲ្យពូធ្វើភ្ជួររាស់នឹងអ្នកណាគេ?

យ៉ន : អានឹងពួកប្រជាជនដែលគេមកពីក្រោមនោះៗ

ធានី : មកពីក្រោម?

យ៉ន : បាទ!

ធានី : ឈ្មោះអីគេ?

យ៉ន : ឈ្មោះ ពួកច្រើន ពួកបុិសាំៗ

ធានី ៖ សាំ ប្រធានសង្កាត់នឹង?

យ័ង ៖ បាទ! ហ្នឹងឯង ។

ធានី ៖ ក្រៅពីសាំ មានអ្នកណាគេទៀតទេ? សាំចាត់ចែងឲ្យពូធ្វើអីគេ

យ័ង ៖ នែក! កាលពីមុនដំបូងនោះឲ្យខ្ញុំកាន់ចបកាប់បិទភ្លឺប្រព័ន្ធស្រែ ។

ធានី ៖ បន្ទាប់មកទៀត គេឲ្យពូធ្វើអីទៀត?

យ័ង ៖ បាទ! មានឲ្យធ្វើអីទេ តែព្រឹកឡើងចាប់ចបកាប់បិទភ្លឺៗទាំងអស់គ្នា ទាំងភូមិទាំងស្រុកប្រព័ន្ធដីជាហិចតាៗ ។

ធានី ៖ ចុះក្រៅពីសាំហើយមានអ្នកណាគេផ្សេងទៀត?

យ័ង ៖ ក្រៅអ្នកណា?

ធានី ៖ ក្រៅពីសាំ ហើយមានអ្នកណាផ្សេងទៀត ដូចថាសាំមេចឹងទៅ អ្នកក្រោមសាំនឹង?

យ័ង ៖ សាំនោះ តាលុត ។

ធានី ៖ តាលុតអ្នកណាគេ?

យ័ង ៖ តាលុតគេអ្នកមកពីខាងនោះមក គេមកខាងក្រោម ។

ធានី ៖ សាំនឹងមកពីភូមិភាគណាវិញ?

យ័ង ៖ មកពីភូមិភាគ មកពី ។

ធានី ៖ ពាយ័ព្យ ឬក៏បូព៌ា ឬក៏និរតី?

យ័ង ៖ បូព៌ា ពីនោះមកពីក្រោម ពីខេត្តសៀមរាប ពីខាងកំពង់ធំ កំពង់អីនោះនឹងគេដឹងអី ។

ធានី ៖ សាំ គាត់អ្នកសៀមរាប?

យ័ង ៖ បាទ!

ធានី ៖ ចាំ! ហើយចឹងគាត់មកពីបូព៌ា ឬក៏មកពីពាយ័ព្យ?

យ័ង ៖ មិនដឹងមកពីខាងណា គេមកពីខាងនោះ គេឡើងមកគេកាន់កាប់ ។

ធានី ៖ ចុះលុតនឹង លុតៗចឹង លុតនឹងគេជារងរបស់សាំ ឬជាអ្នកណាគេ?

យ័ង ៖ រងៗរបស់សាំ ។

ធានី ៖ រងរបស់សាំ?

យ័ង ៖ បាទ!

ធានី ៖ ក្រៅពីសាំ មានអ្នកណាលើសាំនឹងទៀតទេ?

យ័ង ៖ ក្រោយមកត្រង់នេះទៅ បានមកទៀតច្រើនណាស់អ្នកកាន់កាប់ ។

ធានី ៖ សាំ គេហៅគណៈឃុំ គណៈសង្កាត់?

យ៉ន ៖ បាទ! គណៈសង្កាត់ ។

ធានី ៖ ចុះគណៈសហករណ៍ អ្នកណាគេ?

យ៉ន ៖ សហករណ៍ កាលនោះមិនដឹងណា តាខននេះឯង ។

ធានី ៖ សហករណ៍ឃុំគុំរូយើង?

យ៉ន ៖ ទេ! គេអ្នកមកពីនោះទាំងអស់ ខ្ញុំមិនសូវស្គាល់គេផង ស្គាល់តែតាសាំដែលថាគាត់ចុះធ្វើប្រធានកងប្រធានអីចឹងទៅដឹកនាំក៏បេះទៅតាមគេទៅ ។

ធានី ៖ ចឹងពូទទួលបញ្ជាពីសាំផ្ទាល់?

យ៉ន ៖ ទេ! មិនទទួលស្គាល់ ទទួលដែលគេដាក់មកតាមកូនកងគេទៅ ខ្ញុំជាកូនកងគេនាំទៅណាក៏ទៅៗ

ធានី ៖ ចុះប្រធានរបស់ពូអ្នកណាគេ?

យ៉ន ៖ ប្រធានៗទៅក្នុងភូមិឯងតាវើយ អឺ! តាវើយ ។

ធានី ៖ តាវើយ?

យ៉ន ៖ បាទ!

ធានី ៖ អាហ្នឹងគេហៅកងអីគេ កងរបស់ពូនឹងហៅកងអី?

យ៉ន ៖ កងខាងភ្ជួរ ។

ធានី ៖ កងខាងភ្ជួរ?

យ៉ន ៖ បាទ! កាលហ្នឹងម៉ាកងៗនឹងមាន៣០នាក់ដឹកនាំៗ ។

ធានី ៖ ពូមានងាររជាអី អនុគេឬក៏?

យ៉ន ៖ អត់ទេ ខ្ញុំអត់ដែលបានធ្វើអីទេ ។

ធានី ៖ ធ្វើៗ?

យ៉ន ៖ ខ្ញុំសុខចិត្តភ្ជួរតែរាស់ គេដឹកនាំទៅណាក៏ទៅនោះ ។

ធានី ៖ ចឹងតាវើយប្រធានកងភ្ជួរនឹង ចុះអ្នកណាគេជាអនុ?

យ៉ន ៖ កាលនោះមិនមានអ្នកណាអនុទេ គេដាក់តែប្រធានកងមួយៗប៉ុននោះ ។

ធានី ៖ មាន៣០នាក់ចឹងពូ?

យ៉ន ៖ បាទ!

ធានី ៖ ចុះតាវើយនឹង រាល់ថ្ងៃនៅរស់អត់?

យ៉ន ៖ បាទ! ខូចហើយ ។

ធានី ៖ តាវើយ បន្ទាប់មកទៀតអីទេ បន្ទាប់មកធ្វើអីទៀត?

យ៉ន ៖ បាទ!

ធានី ៖ ក្រៅពីការងារក្រួរមានធ្វើអីផ្សេងទៀតអត់?

យ៉ន ៖ ការងារក្រួររួចគេចាត់ឲ្យទៅនៅភ្នំស្រុកនោះ ខ្ញុំវែកដី១ក្នុងម៉ាថ្ងៃមុនដំបូងឲ្យ៥០គីឡូ ដល់៥០គីឡូរួចពីថ្ងៃដាក់ដល់៨០គីឡូ វែកដីដាក់ស្រូវ១រាល់ថ្ងៃរៀងដល់ទាល់ដល់យួនចូលដល់ ជិតដល់យួនចូលមកនេះបានខ្ញុំមកនេះ។

ធានី ៖ ចឹងពូមេភូមិគំរូយើងកាលសម័យនឹងអ្នកណាគេ?

យ៉ន ៖ បាទ!

ធានី ៖ មេភូមិគំរូយើងកាលសម័យនឹង?

យ៉ន ៖ មេភូមិនោះ មេភូមិគំរូ ឈ្មោះ តុ គាត់ទៅសហករដ្ឋហើយ។

ធានី ៖ ឈ្មោះអីគេ?

យ៉ន ៖ ឈ្មោះ តុ។

ធានី ៖ តា តុ?

យ៉ន ៖ តុ។

ធានី ៖ តុ នឹងជាមេភូមិ?

យ៉ន ៖ បាទ!

ធានី ៖ ចុះបន្ទាប់ពីមេភូមិនឹង មកមានអ្នកណាគេទៀតអត់?

យ៉ន ៖ ប៉ុនកាលនោះមេភូមិប៉ុននោះ គាត់មេភូមិមួយគ្រាន់តែថាសម្រាប់តែថាគេបញ្ជាមក ថាឲ្យគេសម្រាប់ចាត់ចែង ថាឲ្យធ្វើស្រែធ្វើចំការធ្វើអីនឹងគោរពតាមគេនឹង។ គឺតថាវេទនាណាស់សម័យនោះ។

ធានី ៖ សម័យនោះវេទនាយ៉ាងម៉េចពូ?

យ៉ន ៖ វេទនាត្រង់បាយទឹក។

ធានី ៖ យ៉ាងម៉េច បាយទឹកយ៉ាងម៉េច?

យ៉ន ៖ បាយទឹកជួនកាលដែលថាបាយដែលវាមិនគ្រប់មិនគ្រាន់ចេះទៅ ជួនកាលស្រូវម៉ាស្លាបព្រាម្នាក់ ច្រូតស្រូវបានដាក់ក្បង់ដៃ។

ធានី ៖ ស្រូវនឹង យកមកហូបម៉េច?

យ៉ន ៖ យកមកហូប។

ធានី ៖ ទាំងអង្កាមទាំងអី?

យ៉ាំង ៖ បាទ! ទាំងអង្កាមទាំងអីទាំងអស់ ។

ធានី ៖ គេឲ្យហូបដែរ?

យ៉ាំង ៖ បាទ! គេឲ្យហូប ។

ធានី ៖ ចុះពូថាឪពុកម្តាយពូ ដែលស្លាប់នៅសម័យខ្មែរក្រហម ស្លាប់ពេលណាដែរ?

យ៉ាំង ៖ ស្លាប់ឆ្នាំ៧៥ ។

ធានី ៖ ១៩៧៥?

យ៉ាំង ៖ បាទ!

ធានី ៖ ដោយសារអីគេទៅ?

យ៉ាំង ៖ ដោយសាររឿងអត់បាយហ្នឹង ។

ធានី ៖ កាលមុនពូមានបានជួយអីគាត់មុនពេលគាត់ស្លាប់ទេ?

យ៉ាំង ៖ បាទ! គ្មានអ្នកណាបានជួយទេ កាលសម័យនឹង ពីព្រោះកូនចៅរៀងៗតែខ្លួនទៅគ្រាប់តែគេប្រើទៅណាក៏ទៅៗ ។

ធានី ៖ ចុះបងប្អូនពូដែលស្លាប់នៅសម័យខ្មែរក្រហមនឹងដោយសារអីដែរ?

យ៉ាំង ៖ ដោយសាររឿងអត់បាយ ។

ធានី ៖ ឆ្នាំប៉ុន្មានដែរ?

យ៉ាំង ៖ ឆ្នាំ៧៦ ៗម្នាក់នោះទៀត ២នាក់នោះ៧៨ ។

ធានី ៖ ហើយដល់ពេលម្នាក់ទៀត?

យ៉ាំង ៖ រឿងឆ្នាំងាប់២នាក់ ។

ធានី ៖ ឆ្នាំទី១ ៧៦ម្នាក់?

យ៉ាំង ៖ បាទ!

ធានី ៖ ដល់៧៨ ២នាក់?

យ៉ាំង ៖ ២នាក់ ។

ធានី ៖ ក្រែងទាំងអស់៤នាក់?

យ៉ាំង ៖ ៤នាក់ ។

ធានី ៖ ម្នាក់ទៀតនៅពេលណា?

យ៉ាំង ៖ ម្នាក់ទៀតអានឹងស្លាប់អាជិតចុង៧៩ ហើយ ។

ធានី ៖ ៧៦ម្នាក់ ស្រី ប្រុស ៧៦នឹង?

យ៉ន ៖ នែក! ប្រុស២ ស្រី២ ។

ធានី ៖ ៧៦នឹងស្លាប់ពេលណា ដូចថាប្រុស ហើយស្រី?

យ៉ន ៖ ៧៦នឹង ឈ្មោះនែក!សំបូរ ។

ធានី ៖ សំបូរ ស្រី ហើយប្រុស?

យ៉ន ៖ ស្រី ។

ធានី ៖ បន្ទាប់មកទៀត ចុង៧៧នឹង២នាក់នឹងស្រី ហើយប្រុស?

យ៉ន ៖ នែក! ២នាក់នឹង ៧៩ម្នាក់ ។ មិញដាក់អត់៧៩?

ធានី ៖ អត់ផង មិញពូថា៧៦?

យ៉ន ៖ ៧៦នោះ នែក! ស្រី ៧៩នោះប្រុស ។

ធានី ៖ មាន៧៩មួយទៀត?

យ៉ន ៖ បាទ!

ធានី ៖ ប្រុស ដល់ពេលចុង៧៧ ស្រីមួយ ប្រុសមួយ?

យ៉ន ៖ បាទ! ៤នាក់ ។

ធានី ៖ សុទ្ធតែស្លាប់ដោយសារអត់បាយទាំងអស់?

យ៉ន ៖ បាទ!

ធានី ៖ បន្ទាប់មទៀតម៉េចទៀត ឆ្នាំប៉ុន្មានដែលគេឲ្យពូទៅភ្នស្រុកវែកដីនឹង?

យ៉ន ៖ មកដល់ឆ្នាំ៧៨ ។

ធានី ៖ វែកដីនៅកន្លែងណាទៅ?

យ៉ន ៖ បាទ! នៅ ។

ធានី ៖ ភ្នំស្រុក?

យ៉ន ៖ ត្រពាំងថ្ម ។

ធានី ៖ ត្រពាំងថ្មកន្លែងលើកទំនប់គេតើ?

យ៉ន ៖ បាទ! នោះហើយលើកអាទំនប់នឹងឯង ។

ធានី ៖ លើកទំនប់ ឬវែក ពូថាវែកដីដាក់ស្រែ?

យ៉ន ៖ វែកដី ប៉ុនដែលគេបិទទំនប់មុនចេះទៅ គេធ្វើរួចហើយ ដល់នេះគេធ្វើស្រែប្រាំង ខ្ញុំវែក ។

ធានី ៖ វែកដីដាក់តាមទំនប់?

យ៉ង ៖ បាទ!

ធានី ៖ ចឹងពេលនឹងទំនប់ត្រពាំងថ្មធ្វើហើយៗ?

យ៉ង ៖ បាទ! ធ្វើហើយ ។

ធានី ៖ ពូបានចូលរួមសម្ពោធន៍នឹងគេទេ?

យ៉ង ៖ នែក! ខ្ញុំអត់បាននៅទេ ខ្ញុំនៅខាងប្រឡាយនេះ ។

ធានី ៖ ប្រឡាយអីគេ?

យ៉ង ៖ ប្រឡាយតាបាន ឲ្យជីៗបេះ ។

ធានី ៖ ពេលពូនៅធ្វើស្រែ ពូដឹងថាត្រពាំងថ្មនឹងជាកន្លែងអីគេទេ?

យ៉ង ៖ ដឹង កន្លែងៗសម្រាប់ធ្វើស្រែប្រាំង ។

ធានី ៖ ពូស្គាល់មេគណៈស្រុកៗ?

យ៉ង ៖ អូ! ខ្ញុំមិនដែលស្គាល់ទេ ។

ធានី ៖ ចឹងគណៈសហករណ៍?

យ៉ង ៖ សហករណ៍ប្រធានសហករណ៍នេះ ភ្លេចឈ្មោះគាត់ហើយ វាយូរហើយ សហករណ៍តាម៉េត ។

ធានី ៖ តាម៉េតៗ?

យ៉ង ៖ បាទ!

ធានី ៖ តាម៉េតសហករណ៍អីគេ សហករណ៍គំរូ?

យ៉ង ៖ សហករណ៍គេក្តាប់ក្នុងម៉ាកន្លែងនឹង ។

ធានី ៖ គេហៅសហករណ៍អី សហករណ៍គំរូ ឬសហករណ៍ថ្មពួក?

យ៉ង ៖ សហអានោះកន្លែងៗគេក្តាប់ធំ ។

ធានី ៖ ហ្នឹងគេហៅសហករណ៍អីគេទៅ?

យ៉ង ៖ ប៉ុនដល់ភ្លេចឈ្មោះគាត់ ឈ្មោះតាដឹងឈ្មោះគាត់អានោះប្រធានសហករណ៍គំរូ ។

ធានី ៖ ចឹងតាម៉េតនឹងសហករណ៍ក្តាប់រួម?

យ៉ង ៖ បាទ!

ធានី ៖ មិនមែនគំរូទេ? ចុះពូដល់ពេលពូធ្វើនៅនឹងដល់ឆ្នាំ៧៨ ពូថាធ្វើនៅនឹងរហូតធ្វើនៅនឹងហើយទៅណាទៀតទៅ?

យ៉ង ៖ ធ្វើនៅនេះបានត្រឡប់មកវិញកាលនោះសម័យ៧៩ ខ្ញុំបងប្អូនយើងរត់ទៅលិចនោះ ។

ធានី ៖ ទៅណាវិញទៅ?

យ៉ន : ទៅនៅតាមដុបតាមព្រៃខ្វាចៗគ្រាប់ខ្វាចរំសេវ នឹងបានយួនចូលមកត្រង់នេះបាននាំគ្នាសំរុកមកពីព្រៃមកៗរកយួននេះវិញ ។

ធានី : ឆ្នាំប៉ុន្មានដែរ ចុះម៉េចបានពួរត់ ឆ្នាំ៧៨ពួនៅនោះហើយ ម៉េចបានពួរត់ ឆ្នាំប៉ុន្មានពួរត់?

យ៉ន : អាចុងអាដើមឆ្នាំបានវាមកនេះៗបាន ដល់អាចុងឆ្នាំនេះមកនេះៗបានៗ ។

ធានី : ដល់ឆ្នាំ៧៩ ឬ៧៨?

យ៉ន : ៧៨ ចុងឆ្នាំ៧៨ ។

ធានី : ចុងឆ្នាំ៧៨នៅណា?

យ៉ន : ដើមឆ្នាំ៧៨វែកជីនៅនោះហើយ ។

ធានី : ដល់ពេលចុងឆ្នាំរត់មកផ្ទះយើង ។

យ៉ន : អាចុងឆ្នាំរត់មកផ្ទះនេះដល់យួនចូលមកនេះបាន ។

ធានី : រត់ទៅវិញ?

យ៉ន : បានរត់បកទៅនោះ ។

ធានី : ហើយថីបានយួនចូលមកម៉េចបានពួរត់ចឹង?

យ៉ន : ដែលយួនមកផ្ទើលខ្វាចៗគ្រាប់កាំភ្លើងខ្វាចអីនឹង ខ្វាចអាពួកខ្មែរក្រហមបាញ់គ្នា ក៏នាំគ្នាភៀសខ្លួនទៅស្រុកទៅភូមិនេះឯង ។ នេះបានត្រឡប់ដឹងថាយួនមិនឲ្យនេះទៅ មានបរទេះមកស្រុកវិញ មកចូលមកខាងយួននេះវិញ ។

ធានី : ចុះកាលដំបូងម៉េចបានរត់ទៅ ចេញពីយួនហើយរត់មកយួនវិញចឹង?

យ៉ន : រត់ៗខ្វាចអាពួកខ្មែរក្រហមនេះ យួនវាឡើងមកទទួលទប់ នេះឯងនៅកណ្តាល គេចឲ្យតែផុតសិន ។

ធានី : គេចទៅណាវិញ?

យ៉ន : គេចទៅនៅអីហៅត្រពាំងយាយនឹម នេះដល់នេះទៅមកពីនោះវិញ ខាងនេះបានដឹងថាយួនមិនឲ្យ បានរត់មកនៅនេះវិញ ។

ធានី : យួនមិនឲ្យនៅអី នៅណា?

យ៉ន : រត់មករកយួននេះ បានយួននេះវាបាញ់តគ្នា បានយួនឃើញប្រជាជនចេះបានគៀបប្រជាជន ទៅនៅនឹងស្វាយ ។

ធានី : អូ!ចឹងពួទៅដល់ស្វាយដែរ?

យ៉ន : បាទ! ដល់ស្វាយនៅស្វាយ ។

ធានី ៖ ហើយម៉េចទៀតទៅពូ?

យ៉ង ៖ ទៅដល់ស្វាយនោះ ខ្ញុំក៏ទៅដល់អាប្អូននោះក៏ អាកូននោះក៏បះរយោសត្រង់នេះអស់ យកទៅដេកពេទ្យស្វាយនោះ ដេកពេទ្យវៀតណាមយើងនេះហើយ ខាងនេះដល់នោះទៀតក៏ នែក! ប្អូនស្រីនោះក៏ត្រូវគ្រាប់ក្បាល ប្អូនស្រីដែលនៅស្វាយនោះត្រូវគ្រាប់កណ្តាលក្បាល យកប្អូនស្រីនោះទៅព្យាបាលពេទ្យកម្ពុជាយើង ព្យាបាលបានជាទាំងអស់ដល់នេះត្រឡប់មកវិញ បានស្រុកស្រួលបួលប៉ុននោះឯង ។

ធានី ៖ ចឹងពេលពូមកដល់ភូមិវិញ អត់មានធ្វើការងារអីទៀតទេ?

យ៉ង ៖ អត់ទេ មានធ្វើតែនេះ ធ្វើតែស្រែចំការ ។

ធានី ៖ ចុះពូបានចូលរួមធ្វើទាហាននឹងគេ កាលសម័យ៧៩?

យ៉ង ៖ អត់ទេ ខ្ញុំអត់ដែលបានធ្វើទេ ។

ធានី ៖ អត់បានធ្វើទេ?

យ៉ង ៖ ខ្ញុំធ្វើតែស្រែចំការរហូត ។

ធានី ៖ ធ្វើស្រែចំការរហូត?

យ៉ង ៖ បាទ!

ធានី ៖ ចុះពេលពូមកដល់ភូមិវិញ អត់មានការប្រទូងប្រទាសគ្នារវាងប៉ាវ៉ាអីខ្មែរក្រហមអីអត់មានទេនៅភូមិយើង អត់មានទេ?

យ៉ង ៖ បាទ! ភូមិយើងមានដែរ ប៉ុនមានតាមតែគេខាងៗ ។

ធានី ៖ មាននឹងគេធ្វើម៉េចទៅពេលដែលគេចូលមកដល់ ដូចថាពេលដែលគេចូលមកដល់ ដូចថាខាងខ្មែរក្រហមចូលមក អ្នកភូមិធ្វើម៉េច ដូចពូធ្វើម៉េច ហើយដល់ពេលប៉ាវ៉ាចូលមកធ្វើម៉េច?

យ៉ង ៖ មកទៅក្រាប ជួនកាលនាំគ្នាក្រាបទៅ គេសួរចេះតែនិយាយនឹងគេទៅ ដល់ពេលគេបាញ់ជាមួយនឹងពួកកងពល ក៏ប្ងន់សេរករត់ចូលណា ។

ធានី ៖ កងពលៗអីគេពូ?

យ៉ង ៖ កងពលខាងនេះឯង ខាងវៀតណាម ។

ធានី ៖ ចឹងចុះដែលធ្លាប់ប៉ាវ៉ា ហើយខ្មែរក្រហនមជួបគ្នាអីទេ នៅភូមិយើង?

យ៉ង ៖ ជួបគ្នា បាត់គ្នានៅសាលាស្រុកនេះម្តង ២ដង ។ នេះប្រជាជននៅតាមផ្ទះនេះចេះ ក៏មានត្រង់សេរនាំគ្នារត់ចូល ដល់គេឈប់បាញ់ក៏នាំដាំបាយស៊ីទៅ ។

ធានី ៖ ចុះកាលនឹងមានហូបចុកគ្រប់គ្រាន់ដែរ?

យ៉ន ៖ បាទ! សព្វថ្ងៃនឹង ។

ធានី ៖ អត់ទេ កាលសម័យនឹង?

យ៉ន ៖ កាលមកសម័យក្រោយពីនែក!ហេងសំរិន ដែលរំដោះបានហើយ ម៉ាឆ្នាំនឹងអត់បាយគ្រប់តែគ្នានឹងឯង នាំគ្នារត់ដែលបារាំងបើកឲ្យនាំគ្នារត់ទៅរែកជញ្ជូនយកមក ។

ធានី ៖ នៅណាវិញ?

យ៉ន ៖ នៅនោះនៅស្រុកថៃ ដែលបារាំងកាលនឹងបើកអង្ករឲ្យ ដែលស្រណោះប្រជាជនកម្ពុជាយើងវាអត់ឃ្លាន ។

ធានី ៖ នៅស្រុកថៃ នៅភូមិឃុំអីដែរ នៅដីរំអីគេ?

យ៉ន ៖ ដីរំសាយធូ.... ។

ធានី ៖ យើងមិនមែនអ្នកនៅក្នុងដីរំនឹងគេបើកឲ្យដែរ?

យ៉ន ៖ បាទ! បើកឲ្យអ្នកស្រុកស្រែកយើង ទៅដល់តំរង់ជួនបានបើកឲ្យ អង្ករម្នាក់ម៉ាការ៉ុងៗ ។

ធានី ៖ ម៉ាការ៉ុងនឹងប៉ុន្មានគីឡូ?

យ៉ន ៖ ម៉ាការ៉ុងនឹងបើគិតទៅម៉ាបាវនឹងចែកគ្នា៤នាក់ ។

ធានី ៖ ម៉ាបាវមានប៉ុន្មានគីឡូដឹងទេ?

យ៉ន ៖ ម៉ាបាវមិនដឹងទេ អត់ដឹងទេរឿងនឹង ។

ធានី ៖ ច្រើនទេដូចម៉ាបាវស្រូវយើងទេ?

យ៉ន ៖ អាម៉ាបាវមិនដល់ស្រូវយើងទេ រៀង៤ម៉ែត្រធំៗ ។

ធានី ៖ បាវតូច បាវធំ?

យ៉ន ៖ មិនបានទេ បានអ្នកម៉ាការ៉ុងកន្លះការ៉ុងគគីរយើងនឹង ។

ធានី ៖ ចឹងច្រើនដែរ?

យ៉ន ៖ បាទ! នេះក៏បានរហេមរហាម ទម្រាំបានទៅរកអង្ករបានមកស៊ីនោះបានបរទេសបានអីគេដឹក ទៅយកអង្ករ យកម្ហូបរៀងៗខ្លួន ។

ធានី ៖ ចឹងពូមិនមែនធ្វើមេភូមិអីនៅសម័យនឹងទេ?

យ៉ន ៖ បាទ! កាលនោះខ្ញុំអត់បានធ្វើទេ ។

ធានី ៖ ចុះមកដល់រាល់ថ្ងៃពូធ្វើការងារអីដែរ?

យ៉ន ៖ ខ្ញុំសព្វថ្ងៃ គ្មានបានធ្វើការងារអីទេ ធ្វើតែស្រែ ហើយនឹងកសិករចំការដែលជួយជារបស់របរតិចតួច ដែលចិញ្ចឹមមានចិញ្ចឹមទាអី ។

ធានី ៖ អូ! ចិញ្ចឹមមាន់ ធ្វើជាកសិករផង ជាអ្នកចិញ្ចឹមសត្វចិញ្ចឹមអីផង?

យ៉ន ៖ បាទ! ចិញ្ចឹមសត្វ គ្រាប់តែដោះស្រាយជីវភាព ជាការបណ្ដោះ ។ នេះទ្រង់មាន់ខ្ញុំ ។

ធានី ៖ ចឹងបានន័យថាពូការសម័យខ្មែរក្រហម ពូអត់បានធ្វើការអីនៅសម័យខ្មែរក្រហមទេ?

យ៉ន ៖ បាទ!

ធានី ៖ ដល់ពេលក្រោយមកក៏អត់បានធ្វើអីដែរ អត់មានធ្វើទាហានខ្មែរក្រហមធ្វើអី ពេលច្បាំងជាមួយវៀតណាមក៏អត់ដែរ?

យ៉ន ៖ អត់ទេ ខ្ញុំមិនដែលទេ ។

ធានី ៖ ចុះខោអាវទាហានដែលពូពាក់នឹងបានមកពីណាវិញ?

យ៉ន ៖ អានេះបង ។

ធានី ៖ បងរបស់ពូដែលធ្វើ?

យ៉ន ៖ អឺ!ប្អូន ។

ធានី ៖ ប្អូនពូគាត់អ្នកធ្វើទាហានដែរ?

យ៉ន ៖ ទាហាន ។

ធានី ៖ ទាហានខាងណាវិញ?

យ៉ន ៖ ទាហានខាងនែក! ហ៊ុន សែន នេះប្អូនចេះតែឲ្យពាក់គ្រាន់ធ្វើស្រែធ្វើអីទៅណា ។ ប្អូនថាបើពាក់សក្តិអាមានផ្លាកចេះៗដែលហ៊ាន ។

ធានី ៖ អូ! ហែកចោលហើយ កាលមុនមានផ្លាក?

យ៉ន ៖ បាទ! បើមានផ្លាក ខ្ញុំមិនមែនទាហាននោះ ។

ធានី ៖ អូ! ខ្លាចគេចាប់?

យ៉ន ៖ បាទ! ខ្លាចគេថាគេអី ។ បាទ! ប្អូននៅនោះឯងនៅភ្នំពេញ ។

ធានី ៖ ចឹងពូនៅសម័យខ្មែរក្រហមអត់មានការ ធ្វើជាអ្នកគ្រប់គ្រងភូមិអីក៏អត់ដែរមើលប្រជាជនក្នុង ភូមិក្តាប់ហូបបាយហូបអីក៏អត់ដែរ?

យ៉ន ៖ បាទ!

ធានី ៖ អត់អីទេ គ្រាន់តែចង់សួរបញ្ជាក់ពូឲ្យច្បាស់ពីមុខការសម័យនឹង ដើម្បីដឹងថា ពូមិញថាពូធ្វើនៅកងភ្ជួរអីចឹង ។ ចង់សួរពូថាក្រៅពីការងារភ្ជួរនឹងមានធ្វើការអីអត់នៅក្នុងសហគមន៍ភូមិយើងអត់ ។

យ៉ន ៖ អត់ទេ ។

ធានី ៖ ចឹងចង់សួរចិត្តពូ តាំងពីមុនរហូតមកដល់ឥឡូវ តើពូយល់ថារបប ដូចថាចិត្តរបស់ពូៗយល់ម៉េច
ដែរ ចំពោះការរស់នៅក្នុងសម័យអស់នឹង?

យ៉ង ៖ បាទ! សម័យអស់នេះដូចថាវាស្រួល ដូចថាវាមិនលំបាក មិនយ៉ាប់ធ្វើស្រែតាមដំណើរ ។

ធានី ៖ ពីមុនហើយឥឡូវ ពូគិតថាមួយណាល្អសព្វថ្ងៃ?

យ៉ង ៖ គិតថាសព្វថ្ងៃស្រួល ម៉េចថាសព្វថ្ងៃស្រួល កាលពីនេះវាសំបូរថាចោរ ។

ធានី ៖ សម័យណាភូមិចោរ?

យ៉ង ៖ ទេ! សម័យមុនៗសំបូរចោរ ។

ធានី ៖ សម័យណា?

យ៉ង ៖ ដល់សព្វថ្ងៃចេះមានអីចោរបាត់ ស្ងាត់ជ្រៀបដេកតាមស្រែតាមដុបតាមអីស្រួល យកគោ យកក្របីទៅដេកក៏មិនដែលមានក្លាក់ផ្អើលអី ។

ធានី ៖ ចុះសម័យខ្មែរក្រហមមានចោរដែរ?

យ៉ង ៖ មាន ។

ធានី ៖ មានៗមកពីណា? ម៉េចបានមាន?

យ៉ង ៖ មានដែលវាប្រឆេះប្រឆាស់គ្នា ។

ធានី ៖ ឆ្លាស់គ្នាម៉េចទៅ?

យ៉ង ៖ ឆ្លាស់គ្នាដែលវាប្រទាញប្រទុងជាមួយពួកនឹង ។

ធានី ៖ មិនមែនទេ កាលសម័យ៣ឆ្នាំ សម័យនឹងមានចោរអត់?

យ៉ង ៖ វាអាក្រោយ ។

ធានី ៖ ចឹងក្នុងសម័យនឹងអត់មានចោរដែរ?

យ៉ង ៖ បាទ! សព្វថ្ងៃស្រួល នឹងថាសម័យសព្វថ្ងៃស្រួលអត់មានចោរមានអីទេ ដេកតាមដុបតាមព្រៃ ភ្នំរាស់ទៅណាស្រួល ។

ធានី ៖ ចឹងពូនៅក្នុងសម័យ៣ឆ្នាំនឹង ពូដែលធ្លាប់ជួយអ្នកណាទេ ជួយឲ្យជាម្ហូបអាហារ ឬក៏ឲ្យរួចជីវិត អីចឹងមានទេ?

យ៉ង ៖ អូ! សម័យនោះសូម្បីតែឪពុកម្តាយក៏មិនដឹងជាជួយម៉េចវារកតែខ្លួនរួចនោះ ព្រោះបាយ នោះម្នាក់ម៉ាវែក មិនមែនបាយៗរឹងយើងបាយបបរម្នាក់ម៉ាវែកៗ គ្មានអ្នកណាបានឆ្អែតណា យករស់រៀងខ្លួន សូម្បីតែឪពុកម្តាយខ្ញុំមិនដឹងជាជួយម៉េច ។

ធានី ៖ ចុះពូកាលពេលនៅធ្វើដាក់ជីភ្នំស្រុកនឹងអ្នកណាប្រធានពូដែរ ?

យ៉ង ៖ ខ្មោចតាពាត់ ។

ធានី ៖ តាព័ន្ធ?

យ៉ង ៖ បាទ!

ធានី ៖ អីគេព័ន្ធ?

យ៉ង ៖ តាពាត់ មិនដឹងស្អីគេពាត់ទេ នៅថ្មពួក ប៉ុនគាត់ខូចហើយ ។

ធានី ៖ អានឹងគេហៅប្រធានអីគេ?

យ៉ង ៖ ប្រធានក្រុម ។

ធានី ៖ ប្រធានក្រុមអីគេ?

យ៉ង ៖ ប្រធានក្រុមដែលខាងវែកជញ្ជូនដី ។

ធានី ៖ ពូខ្ញុំអស់អីសួរពូហើយ ពូមានអីចង់សួរខ្ញុំវិញ ឬក៏មានសំណូមពរអីអត់?

យ៉ង ៖ បាទ! ខ្ញុំមិនមានអីនេះទេ សូមឲ្យតែចង់ឲ្យបានសុខស្រួលសប្បាយដូចសព្វថ្ងៃចេះ ខ្ញុំអរឡើងថាហាមងាប់ទេ នោះតែប៉ុននេះរស់បានហើយប្រជាជនកម្ពុជាយើង ។

ធានី ៖ ចឹងអរគុណច្រើនពូណា៎ ។

«ចប់»